**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: TRIAL (តែងតែតាមដាននិទណ្ឌភាព)

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:28
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ/សម្ងាត់/សម្ងាត់បំផុត

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាមិនមែនជាភាគី**

---

**ដាក់ដោយ÷**

**មិនមែនជាភាគី**

TRIAL

(តែងតែតាមដាននិទណ្ឌភាព)

**ផ្ញើជូន÷**

**សហព្រះរាជអាជ្ញា÷**

ជា លាង

Robert PETIT

## សេចក្តីផ្តើម និងញត្តិ

*វត្ថុបំណងនៃសារណានេះគឺដើម្បីបញ្ជាក់ថាតើ តាមច្បាប់ទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហាររបស់រដ្ឋ ឬ អង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើ "ប្រជាជនស៊ីវិល" តាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*[1]។

*ដើម្បីធ្វើការបញ្ជាក់នេះ សារណានេះនឹងកំណត់ពីអ្វីដែលជាបទដ្ឋានច្បាប់ត្រឹមត្រូវដើម្បីបកស្រាយទស្សនាទានអំពី"ប្រជាជនស៊ីវិល"តាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*[2] *នៅក្នុងស្ថានភាពដែលកំពុងពិភាក្សា ដោយពិចារណាលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិដែលជាប់ពាក់ព័ន្ធ។*

---

[1] សារណានេះចាប់ផ្តើមដោយសន្មតថា ការវាយប្រហារដែលបានធ្វើឡើងមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធខ្លួនឯងមិនអាចចាត់ទុកថាជាការវាយប្រហារតែមួយប៉ុណ្ណោះនៅក្នុងក្របខណ្ឌនៃការវាយប្រហារទ្រង់ទ្រាយកាន់តែធំដែលសំដៅលើប្រជាជនទូទៅនៅក្នុងប្រទេស។ ក្នុងករណីនេះ មូលដ្ឋានគ្រឹះនៃយុត្តិសាស្ត្រអន្តរជាតិ បញ្ជាក់ថា វត្តមានរបស់បុគ្គលិកយោធាជាគោលដៅមួយនៃការវាយប្រហារនៅក្នុងចំណោមប្រជាជនទូទៅ គឺមិនកែប្រែចរិតលក្ខណៈជាជនស៊ីវិលរបស់ប្រជាជនបានឡើយតាមគោលបំណងនៃនិយមន័យស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សូមមើលតុលាការ ICTY រឿងក្តី រដ្ឋអាជ្ញាតទល់នឹង Tadić សំណុំរឿងលេខ T-94-1-T សាលក្រម ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦៣៨។ សាលក្រម Akayesu កថាខណ្ឌ ៥៨២។ តុលាការ ICTR សាលក្រម Kayishema-Ruzindana កថាខណ្ឌ ១២៨។ តុលាការ SCSL រឿងក្តី រដ្ឋអាជ្ញាតទល់នឹង Sesay និងអ្នកផ្សេងទៀត ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៨២។ តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Bemba Gomb អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ១៥៦។ អ.វ.ត.ក សំណុំរឿងលេខ ០០១ សាលក្រម ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣០៥។

[2] តម្រូវការត្រូវមានការបកស្រាយបែបនេះគឺកំណត់តាមអង្គហេតុដែលថា *"និយមន័យអំពីជនស៊ីវិលនៅក្នុងមាត្រា ៣ រួម មិនអាចអនុវត្តភ្លាមៗមកលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានឡើយពីព្រោះថា វាជាផ្នែកមួយនៃច្បាប់សង្គ្រាម ឬទំនៀមទម្លាប់សង្គ្រាម ហើយអាចអនុវត្តបានតាមសទិសភាពតែប៉ុណ្ណោះ"* តុលាការ ICTY រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Tadić សំណុំរឿងលេខ T-94-1-T សាលក្រម ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦៤៨។

១. ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

១.១ ច្បាប់ចូលជាធរមាន (ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩)

១. ដើម្បីបញ្ជាក់ពីទំនៀមទម្លាប់សិទ្ធិមនុស្សអន្តរជាតិដែលអនុវត្តនៅពេលវេលាពាក់ព័ន្ធនោះ គឺចាំបាច់ត្រូវយោងលើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស[3]។ មានការអះអាងថា នៅត្រឹមឆ្នាំ ១៩៧៥ ប្រទេសកម្ពុជា ជាប់កាតព្វកិច្ចដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ជាពិសេសកាតព្វកិច្ចទាក់ទងនឹងសិទ្ធិរស់រានមានជីវិត(មាត្រា ៣) និងសិទ្ធិមិនត្រូវទទួលរងទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មកាចសាហាវ ឥតមនុស្សធម៌ ឬថោកទាបបានឡើយ (មាត្រា ៥)។

២. ទី១ កម្ពុជា បានចូលជាសមាជិកអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៥៥[4]។ កម្ពុជាប្រជាធិបតេយ្យដែលជាប់កាតព្វកិច្ចអន្តរជាតិដូចព្រះរាជាណាចក្រកម្ពុជា[5]ដែរ ត្រូវមានដែនកំណត់ទាំងស្រុងតាមគោលការណ៍ដែលកំណត់ដោយធម្មនុញ្ញអង្គការសហប្រជាជាតិ[6]។ ហេតុនេះ កម្ពុជាប្រជាធិបតេយ្យ បានទទួលយកគោលការណ៍នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស តាមរយៈសមាជិកភាពរបស់ខ្លួននៅអង្គការសហប្រជាជាតិ។

៣. ទី២ ទោះជាថា នៅឆ្នាំ ១៩៤៨ មាត្រាភាគច្រើននៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សត្រូវចាត់ទុកជាគោលការណ៍ថាមានសារៈសំខាន់ផ្នែកសីលធម៌[7]យ៉ាងណាក៏ដោយ ក៏នៅត្រឹមឆ្នាំ

---

[3] សូមមើលមហាសន្និបាទអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កិច្ចប្រជុំពេញអង្គលើកទី ១៨៣ ទីក្រុងប៉ារីស ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ សេចក្តីសម្រេចលេខ ២១៧ ក (III)។

[4] សូមមើលធម្មនុញ្ញអង្គការសហប្រជាជាតិ សានហ្វ្រានស៊ីស្កូ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៤៥ សេចក្តីប្រកាសទទួលយកកាតព្វកិច្ចនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ-ការចូលជាសមាជិករបស់រដ្ឋនៅក្នុងអង្គការសហប្រជាជាតិ ស្របតាមមាត្រា ៤ នៃធម្មនុញ្ញ សានហ្វ្រាស៊ីស្កូ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៤៥ អាចចូលពិនិត្យមើលបានតាមរយ: http://treaties.un.org/Pages/ViewDetails.aspx?src=TREATY7mtdsg_no=1-2&chapter=17lang=en។

[5] នៅឆ្នាំ ១៩៧៥ ខ្មែរក្រហមបានគ្រប់គ្រងរដ្ឋ ដែលបានផ្លាស់ប្តូរឈ្មោះជាផ្លូវការទៅជាកម្ពុជាប្រជាធិបតេយ្យ ដោយប្រកាសរដ្ឋធម្មនុញ្ញថ្មី នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦។

[6] សូមមើល ជាពិសេស មាត្រា ១(៣)នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

[7] អង្គការសហប្រជាជាតិ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិមនុស្ស ១ ទីក្រុងញ៉ូយ៉ក៖ នាយកដ្ឋានព័ត៌មានសាធារណ: អង្គការសហប្រជាជាតិ ឆ្នាំ ១៩៤៨។

១៩៧៥ មាត្រាទាំងនោះបានឈានដល់ឋានៈជាច្បាប់ទម្លាប់អន្តរជាតិហើយ[8] ហេតុនេះ ខ្លឹមសារនៃមាត្រាទាំងនោះគឺត្រូវជាប់កាតព្វកិច្ចផ្លូវច្បាប់សម្រាប់រដ្ឋទាំងអស់ ដោយមិនគិតពីសមាជិកភាពរបស់រដ្ឋទាំងនោះនៅក្នុងសន្ធិសញ្ញាអន្តរជាតិជាក់លាក់ណាឡើយ។ កម្ពុជា មិនដែលបានជំទាស់ទៅនឹងខ្លឹមសារនៃមាត្រានៅក្នុងសេចក្តីប្រកាសនេះឡើយ។ ផ្ទុយមកវិញ នៅក្នុងសន្និសីទអន្តជាតិស្តីពីសិទ្ធិមនុស្សលើកទីមួយ ធ្វើឡើងនៅទីក្រុងតេអេរ៉ង់ នៅ ឆ្នាំ ១៩៦៨ កម្ពុជា បានចូលរួមអនុម័តដោយឯកច្ឆ័ន្ទលើសេចក្តីប្រកាសដែលបញ្ជាក់ថា *"សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (...) បង្កើតបានជាកាតព្វកិច្ចមួយសម្រាប់សមាជិកសហគមន៍អន្តរជាតិ"*[9]។

១.២ លទ្ធភាពអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិចំពោះករណីជាក់លាក់៖ មិនចាំបាច់ត្រូវមានភាពខុសគ្នាឡើយ

៤. ទាក់ទងនឹងលទ្ធភាពអនុវត្តវិធានសិទ្ធិមនុស្សចំពោះជម្លោះប្រដាប់អាវុធនៅកម្ពុជា មានការអះអាងថា ទំនាក់ទំនងអន្តរកម្មរវាងច្បាប់មនុស្សធម៌អន្តរជាតិ ជាមួយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ត្រូវ

[8] សូមមើលសៀវភៅប្រចាំឆ្នាំអង្គការសហប្រជាជាតិ៖ ឆ្នាំ ១៩៤៨-១៩៤៩ ជំពូក V៖ សំណួរស្តីពីមនុស្សធម៌ វប្បធម៌ និងសិទ្ធិមនុស្ស អាចចូលពិនិត្យមើលបានតាមរយៈ៖ http://www.ohchr.org/EN/UDHR/Pages/Resources.aspx។ សូមមើលផងដែរ តុលាការយុត្តិធម៌អន្តរជាតិ រឿងក្តី សហរដ្ឋអាមេរិក តទល់នឹងអ៊ីរ៉ង់ ឆ្នាំ ១៩៨0 ទំព័រ ៣ និង ៤២ (សាលក្រមចុះថ្ងៃទី ២៤ ខែ ឧសភា)៖ "*ការដកហូតសេរីភាពពីមនុស្សទាំងខុស ហើយបង្ខាំងពួកគេទុកក្នុងស្ថានភាពលំបាក គឺបង្ហាញឱ្យឃើញយ៉ាងច្បាស់ថាមិនស្របតាមគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងគោលការណ៍ជាសារវ័ន្តដែលមានចែងយ៉ាងច្បាស់នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*" (យើងគូសសញ្ញាបន្ទាត់ពីក្រោម)។ សូមមើលផងដែរ Barcelona Traction, Light & Power Co., Ltd, 1970 ICJ 3, ទំព័រ ៣២-៣៤ (ដំណាក់កាលទី ២) (សាលក្រមចុះថ្ងៃទី 0៥ ខែ កុម្ភៈ ឆ្នាំ ១៩៧0)។ ផលលំបាកផ្នែកច្បាប់សម្រាប់រដ្ឋនានាដោយសារអាហ្វ្រិកខាងត្បូង បន្តវត្តមាននៅ ណាមីប៊ី (អាហ្វ្រិកនិរតី)ទោះបីជាមានសេចក្តីសម្រេចលេខ ២៧៦ របស់ក្រុមប្រឹក្សាសន្តិសុខ (ឆ្នាំ ១៩៧0), 1971 ICJ 16, 57 (មតិយោបល់ប្រឹក្សាចុះថ្ងៃទី ២១ ខែ មិថុនា)។ សូមមើលឧទាហរណ៍ Humprehy Waldock សិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិប្រៀបធៀប និងសារៈសំខាន់នៃអនុសញ្ញាអឺរ៉ុបនៅក្នុងអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប ទំព័រ ១ និង ១៥(Bri. Inst. Int'l & Comp. L., លេខ ៥ ឆ្នាំ ១៩៦៥)។ Louis B. Sohn ច្បាប់សិទ្ធិមនុស្ស ធម្មនុញ្ញ, 12 Tex. Int'l L. J., ទំព័រ ១២៩, ១៣៣ (ឆ្នាំ ១៩៧៧)។ Richard Bilder លក្ខន្តិកៈនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ៖ ទិដ្ឋភាពរួម នៅក្នុងឯកសារចំណងជើង ច្បាប់ និងការអនុវត្តសិទ្ធិមនុស្សអន្តរជាតិ ទំព័រ ១ និង ៨ (James Tuttle កែសម្រួល ឆ្នាំ ១៩៧៨)។

[9] សេចក្តីប្រកាសទីក្រុងតេអេរ៉ង់ សកម្មភាពចុងក្រោយនៃសន្និសីទអន្តរជាតិស្តីពីសិទ្ធិមនុស្ស ទីក្រុងតេអេរ៉ង់ ថ្ងៃទី ២២ ខែ មេសា ដល់ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៦៨ ឯកសារ U.N. Doc. A/CONF. 32/42។

តែពិនិត្យដោយគិតលើស្ថានភាពច្បាប់នៅឆ្នាំ ១៩៧៥ និងទង្វើជាក់លាក់ដែលស្ថិតនៅក្រោមការត្រួតពិនិត្យ។

៥. លទ្ធភាពអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិចំពោះស្ថានភាពជម្លោះប្រដាប់អាវុធ ត្រូវបានទទួលស្គាល់ជាសកលរួចហើយនៅត្រឹមឆ្នាំ ១៩៧៥[10]។

៦. ចំពោះច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់វិស័យនេះមានបំណងធ្វើនិយតកម្មលើទង្វើរបស់ភាគីនានានៅក្នុងជម្លោះប្រដាប់អាវុធ[11] ហេតុនេះ ច្បាប់នេះអនុវត្តចំពោះតែទង្វើដែលជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងសកម្មភាពអរិភាពតែប៉ុណ្ណោះ[12]។ ដូច្នេះ ច្បាប់ស្តីពីជម្លោះប្រដាប់អាវុធអន្តរជាតិ ក្រៅពីមានករណីលើកលែងមួយចំនួនតូច គឺមិនអាចអនុវត្តបានឡើយចំពោះទំនាក់ទំនងរវាងរដ្ឋជាមួយនឹងពលរដ្ឋរបស់ខ្លួន ទោះបីជាថា ពលរដ្ឋគឺជាសមាជិកយោធារបស់ខ្លួនក៏ដោយ។

៧. ប្រសិនបើទាំងច្បាប់មនុស្សធម៌អន្តរជាតិ ទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិ អាចអនុវត្តបាននៅពេលនោះក៏ដោយចុះ ក៏មានការអះអាងថា ច្បាប់សិទ្ធិមនុស្សអន្តរជាតិត្រូវតែមានអធិកភាពនៅក្នុងរឿងក្តីដែលកំពុងពិចារណានេះដែរ។ យោងតាមគណៈកម្មការច្បាប់អន្តរជាតិ *"គោលការណ៍ដែលថាច្បាប់ពិសេសធ្វើបដិបញ្ញត្តិពីច្បាប់ទូទៅ គឺជាពាក្យដែលគេទទួលយកជាទូទៅអំពីការបកស្រាយច្បាប់ និងបច្ចេកទេសសម្រាប់ដោះស្រាយជម្លោះដែលជាទំនៀមទម្លាប់"*[13]។ គោលការណ៍ច្បាប់

[10] សូមមើលក្នុងចំណោមនោះមានសេចក្តីសម្រេចលេខ ២៦៧៥ របស់មហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍ជាមូលដ្ឋានសម្រាប់ការពារប្រជាជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ សម័យប្រជុំលើកទី ២៥ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧០។ សេចក្តីសម្រេចលេខ ៣៣១៨ របស់មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាសស្តីពីការការពារស្ត្រី និងកុមារក្នុងគ្រាអាសន្ន និងជម្លោះប្រដាប់អាវុធ សម័យប្រជុំលើកទី ២៩ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៤។ ក្រោយមក ចំណុចនេះត្រូវបានបញ្ជាក់ដោយតុលាការយុត្តិធម៌អន្តរជាតិ នៅក្នុងឯកសារស្តីពីនីត្យានុកូលភាពនៃការគំរាមកំហែង ឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរ មតិយោបល់ប្រឹក្សា ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦ របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ១៩៩៦ កថាខណ្ឌ ២៥។ តុលាការយុត្តិធម៌អន្តរជាតិ ផលលំបាកផ្នែកច្បាប់ដោយសារកសាងជញ្ជាំងនៅដែនដីប៉ាឡេស្ទីនដែលគេកាន់កាប់ មតិយោបល់ប្រឹក្សា ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤ របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ២០០៤។

[11] C. Droege ទំនាក់ទំនងអន្តរកម្មរវាងច្បាប់មនុស្សធម៌អន្តរជាតិ ជាមួយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ នៅក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ, ISR. L. កែសម្រួល វ៉ុល ៤០ លេខ ០២ ឆ្នាំ ២០០៧ ទំព័រ ៣១០។

[12] រឿងក្តី រដ្ឋអាជ្ញាតទល់នឹង Dusko Tadic សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំប្តឹងឧទ្ធរណ៍ជាបន្ទាន់ស្តីពីយុត្តាធិការ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ ៧០។

[13] របាយការណ៍របស់ក្រុមសិក្សានៃគណៈកម្មការច្បាប់អន្តរជាតិ បំណែកនៃច្បាប់អន្តរជាតិ៖ ការលំបាកកើតចេញពីការធ្វើចម្រុះកម្ម និងការពង្រីកច្បាប់អន្តរជាតិ កថាខណ្ឌ៥៦ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦។

ពិសេសនេះ[14] អាចត្រូវចាត់ទុកថាជាទំនៀមទម្លាប់បច្ចេកទេសដោះស្រាយជម្លោះ ដោយក្នុងនោះ ក្នុងចំណោមបទប្បញ្ញត្តិច្បាប់ចំនួនពីរដែលសុទ្ធតែមានសុពលភាព អាចអនុវត្តបាន ហើយគ្មានទំនាក់ទំនងឋានានុក្រមជាមួយគ្នានោះ បទប្បញ្ញត្តិមួយណាដែលមានអានុពលជាង មានភាពច្បាស់លាស់ជាង និងប្រាកដប្រជាជាង ហើយកាន់តែមានលទ្ធភាពអាចពិចារណាលើកាលៈទេសៈពិសេសបាននោះគឺជាបទប្បញ្ញត្តិដែលត្រូវតែមានអធិកភាព[15]។

៨. ហេតុនេះ ចាំបាច់ត្រូវវិភាគប្រព័ន្ធច្បាប់ទាំងពីរនេះតាមវិធានទីមួយៗ ហើយវាយតម្លៃថាតើវិធានមួយណាដែលសមស្របជាង។ នៅក្នុងស្ថានភាពដែលកំពុងពិចារណានេះ វិធានទាំងពីរនេះគឺម្យ៉ាងមាត្រា ៣ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ ដែលមានបំណងឆ្លុះបញ្ចាំងពី“*ការពិចារណាជាមូលដ្ឋានលើមនុស្សធម៌*”[16] និងម្យ៉ាងទៀត គឺមាត្រា ៣ និង ៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រា ៣ រួម កំណត់វិធានការការពារជាមូលដ្ឋានសម្រាប់“ជនដែលមិនបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពអរិភាព” ហេតុនេះ មាត្រានេះផ្តោតលើគំនិតស្តីពីសកម្មភាពអរិភាពរវាងភាគីធ្វើសង្គ្រាម និងមូលហេតុដែលការពារប្រជាជនមួយចំនួនដែលមិនមែន (ឬលែងជា)ការគំរាមកំហែងដល់ខ្មាំង។ ផ្ទុយមកវិញ មាត្រា ៣ និង មាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កំណត់សិទ្ធិជាក់លាក់ដែលមនុស្សមាន ធៀបជាមួយនឹងរដ្ឋរបស់ពួកគាត់ ដោយមិនគិតពីស្ថានភាពដែលពួកគាត់ស្ថិតនៅឡើយ។ អំពើដែលកំពុងពិចារណានេះ ដែលរបបមួយប្រព្រឹត្តឧក្រិដ្ឋកម្មជាទូទៅ និងជាប្រព័ន្ធមកលើយោធាប្រដាប់អាវុធខ្លួនឯងដែលមិនពាក់ព័ន្ធនឹងសកម្មភាពអរិភាព គឺជាអំពើដែលមានអង្គហេតុចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិសិទ្ធិមនុស្សទាំងនេះ។

---

[14] គោលការណ៍នេះមានសុពលភាពរួចហើយនៅពេលវេលាពាក់ព័ន្ធនោះ សូមមើលសេចក្តីថ្លែងការណ៍របស់អ្នកប្រឹក្សាជំនាញ (Waldock) សន្និសីទអង្គការសហប្រជាជាតិស្តីពីច្បាប់សន្ធិសញ្ញា សម័យប្រជុំលើកទី ២ ទីក្រុងវីយែន ថ្ងៃទី ០៩ ខែ មេសា ដល់ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ១៩៦៩ កំណត់ហេតុផ្លូវការ (អង្គការសហប្រជាជាតិ ទីក្រុង ញូយ៉ក ឆ្នាំ ១៩៧០) ទំព័រ ២៧០។

[15] ខាងលើ ជើងទំព័រ ១៥ កថាខណ្ឌ ៦០។

[16] តុលាការយុត្តិធម៌អន្តរជាតិ សកម្មភាពយោធា និងប៉ារ៉ា (ប្រទេសនីការ៉ាហ្គួ តទល់នឹងសហរដ្ឋអាមេរិក) អង្គសេចក្តី របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ ១៩៨៦ កថាខណ្ឌ ១១៣-១១៤។

៩. ដោយសារថា ច្បាប់សិទ្ធិមនុស្សអន្តរជាតិ មិនមានចែងពីភាពខុសគ្នាអំពីឋានៈនោះ[17] ទើបសិទ្ធិជាសារវ័ន្តអាចអនុវត្តបានចំពោះពលរដ្ឋគ្រប់រូបដែលស្ថិតនៅក្រោមយុត្តាធិការរដ្ឋ ដោយមិនគិតថាតើពួកគាត់មានមុខងារប្រយុទ្ធ ឬអត់នោះទេ។

១០. នេះចង់បង្ហាញឲ្យឃើញថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធ គឺជាពលរដ្ឋរួមដែលត្រូវតែទទួលបានការការពារសិទ្ធិជាសារវ័ន្តដូចគ្នានឹងពលរដ្ឋផ្សេងទៀតដែរ[18] ហើយត្រូវចាត់ទុកថាជាជនស៊ីវិលតាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងស្ថានភាពដែលកំពុងពិចារណានេះ។

## ២. ច្បាប់មនុស្សធម៌អន្តរជាតិ

### ២.១ ច្បាប់ជាធរមាន

១១. ដូចបានបញ្ជាក់ដោយ អ.វ.ត.ក ដែរ ស្ថានភាពនៅកម្ពុជានៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ត្រូវបានចាត់ទុកថាជាជម្លោះប្រដាប់អាវុធអន្តរជាតិ[19]។ អនុសញ្ញាទីក្រុងហ្សឺណែវចំនួន ៤ ឆ្នាំ ១៩៤៩ អាចអនុវត្តបានចំពោះជម្លោះនេះ[20] ហើយឆ្លុះបញ្ចាំងពីច្បាប់ទម្លាប់អន្តរជាតិ[21]។ បន្ថែមពីលើនេះទៀត បទបញ្ញាទីក្រុងឡាអេ ដែលជាប់ពាក់ព័ន្ធ[22] គឺជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិផងដែរនៅពេលនោះ[23]។

---

[17] René Provost ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ សារព័ត៌មានសាកលវិទ្យាល័យខេមប្រ៊ីជ ឆ្នាំ ២០០២ ទំព័រ ៤១។

[18] សូមមើលយុត្តិសាស្ត្រនាពេលថ្មីៗនេះ ដូចជា តុលាការកំពូលចក្រភពអង់គ្លេស រឿងក្ដី Smiths និងអ្នកផ្សេងទៀត តទល់នឹងក្រសួងការពារជាតិ កថាខណ្ឌ ៥៤-៥៥ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣។

[19] អ.វ.ត.ក សំណុំរឿងលេខ ០០១ សាលក្រម ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤២៣។

[20] អនុសញ្ញាទាំងនេះត្រូវបានកម្ពុជាផ្ដល់សច្ចាប័ននៅឆ្នាំ ១៩៥៨ ហើយវៀតណាម បានផ្ដល់សច្ចាប័ននៅឆ្នាំ ១៩៥៧។ ក្រោយមក ពិធីសារឆ្នាំ ១៩៧៧ ត្រូវបានផ្ដល់សច្ចាប័ន ហេតុនេះមិនអាចអនុវត្តបានឡើយ។

[21] ដូចខាងលើ ជើងទំព័រ ២១ កថាខណ្ឌ ៤០៥។ បទបញ្ញាទីក្រុងឡាអេ ក៏ជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិនៅពេលនោះផងដែរ។

[22] ជាពិសេស សូមមើល អនុសញ្ញា (IV)ដែលគោរពច្បាប់សង្គ្រាម និងទំនៀមទម្លាប់សង្គ្រាមលើដីគោក និងឧបសម្ព័ន្ធនៃអនុសញ្ញានេះ៖ បទបញ្ញាទាក់ទងនឹងច្បាប់សង្គ្រាម និងទំនៀមទម្លាប់សង្គ្រាមលើដីគោក ទីក្រុងឡាអេ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧។

[23] សូមមើលការជំនុំជម្រះ I លើឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅចំពោះមុខសាលាក្ដីយោធាអន្តរជាតិ កថាខណ្ឌ ២៥៣ (ឆ្នាំ ១៩៤៥)។

## ២.២ ការកំណត់និយមន័យអំពីឋានៈជាសមាជិកយោធា

១២. មាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ III កំណត់និយមន័យថា ឈ្លើយសឹកគឺជា *"ជន (...)ដែលបានធ្លាក់ចូលក្នុងអំណាចរបស់សត្រូវ*[24] ប៉ុន្តែមិនបានកំណត់និយមន័យអំពីពាក្យថា យុទ្ធជន ទេ។ ម្យ៉ាងវិញទៀត បទបញ្ញា ៣ នៃបទបញ្ញាទីក្រុងឡាអេ[25] បញ្ជាក់ថា *"កងកម្លាំងប្រដាប់អាវុធរបស់ភាគីបច្ចាមិត្តអាចមានយុទ្ធជន និងអ្នកដែលមិនមែនជាយុទ្ធជន។ ក្នុងករណីដែលខ្មាំងចាប់បាន ទាំងយុទ្ធជន ទាំងអ្នកដែលមិនមែនជាយុទ្ធជន មានសិទ្ធិទទួលបានការប្រព្រឹត្តិជាឈ្លើយសឹក"*[26]។ ធាតុផ្សំចំនួនពីរត្រូវតែកត់សម្គាល់។ ទី១ លទ្ធភាពដែលសមាជិកនៃកងកម្លាំងប្រដាប់អាវុធមិនអាចត្រូវចាត់ទុកថាជាយុទ្ធជន។ ទី២ មូលហេតុនៃមាត្រានេះ ដែលពឹងផ្អែកលើទំនាក់ទំនងរវាងទាហានរបស់ភាគីបច្ចាមិត្ត ជាមួយនឹងភាគីផ្សេងទៀត។

១៣. មានការអះអាងថា នៅក្នុងស្ថានភាពដែលកំពុងពិចារណានេះ សមាជិកនៃកងកម្លាំងប្រដាប់អាវុធគឺត្រូវចាត់ទុកថាជាជនស៊ីវិល ឬជាទាហានបាត់បង់សមត្ថភាពប្រយុទ្ធចំពោះរដ្ឋខ្លួនឯង ហេតុនេះ ពួកគាត់ត្រូវបានការពារប្រឆាំងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[27]។

### ក) សមាជិកនៃកងកម្លាំងប្រដាប់អាវុធ ក្នុងនាមជាអ្នកដែលមិនមែនជាយុទ្ធជន

១៤. តាមគោលបំណងនៃគោលដៅវាយប្រហារ ជនស៊ីវិលត្រូវការពារ ដរាបណាពួកគាត់មិនចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពអរិភាព [28] (មិនមែនចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពអរិភាព)។ តាមគោលបំណងនៃការបង្ខាំងខ្លួន ជនស៊ីវិលអាចត្រូវចាត់ទុកថាជាជនដែលត្រូវការពារ ស្រប

---

[24] អនុសញ្ញាទីក្រុងហ្សឺណែវ III មាត្រា ៤។

[25] អនុសញ្ញា (IV)ដែលគោរពច្បាប់សង្គ្រាម និងទំនៀមទម្លាប់សង្គ្រាមលើដីគោក និងឧបសម្ព័ន្ធនៃអនុសញ្ញានេះ៖ បទបញ្ញាទាក់ទងនឹងច្បាប់សង្គ្រាម និងទំនៀមទម្លាប់សង្គ្រាមលើដីគោក ទីក្រុងឡាអេ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧។

[26] សូមមើលបទបញ្ញា ៣ អាចចូលពិនិត្យបានតាមរយៈ: https://www.icrc.org/applic/ihl/ihl.nsf/Treaty.xsp?action=openDocument&documentId=4D47F92DF3966A7EC12563CD002D6788។

[27] *គេមិនបានមើលឃើញមូលហេតុដែលថាមានតែជនស៊ីវិល មិនមានយុទ្ធជនទេ ដែលគួរតែត្រូវបានការពារពីវិធានទាំងនេះ(ជាពិសេសវិធានដែលហាមឃាត់ការធ្វើទុក្ខបុកម្នេញ) ដោយពិនិត្យឃើញថា វិធានទាំងនេះអាចចាត់ទុកថាមានវិសាលភាព និងគោលបំណងមនុស្សធម៌ទូលំទូលាយជាងច្បាប់ដែលហាមឃាត់ឧក្រិដ្ឋកម្មសង្គ្រាម"* តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Kupreskić,* IT-95-16-T អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៤៧។

[28] សូមមើលមាត្រា ៣ រួម អនុសញ្ញាទីក្រុងហ្សឺណែវ។

តាមអត្ថន័យនៃមាត្រា ៤ នៃអនុសញ្ញាណទីក្រុងហ្សឺណែវ IV ប្រសិនបើពួកគាត់ត្រូវតាមលក្ខខណ្ឌមួយចំនួន។

១៥. ដោយអនុវត្តបទដ្ឋានទាំងនេះចំពោះសមាជិកនៃកងកម្លាំងប្រដាប់អាវុធចំពោះរដ្ឋខ្លួនឯង គេគួរចាំទុកថា និយមន័យអំពីការចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពអរិភាព រាប់បញ្ចូលទាំងភាពពាក់ព័ន្ធជាមួយនឹងបច្ចាមិត្ត មានន័យថា *"សកម្មភាពនេះត្រូវតែធ្វើឡើងជាពិសេស<u>ដើម្បីបង្កឱ្យមានព្យសនកម្មដោយផ្ទាល់ឱ្យដល់កម្រិតតាមលក្ខខណ្ឌតម្រូវដែលជួយជ្រោមជ្រែងភាគីណាមួយនៅក្នុងជម្លោះ ហើយបំផ្លាញភាគីមួយផ្សេងទៀត</u>"*[29]។ ហេតុនេះ ប្រសិនបើមិនអាចបញ្ជាក់បានថាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ បានធ្វើទង្វើមួយដែលប៉ះពាល់ធ្ងន់ធ្ងរដល់រដ្ឋខ្លួនឯងទេនោះ សមាជិកនោះមិនអាចត្រូវចាត់ទុកថាជាបានចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពអរិភាព តាមគោលបំណងនៃគោលដៅវាយប្រហារបានឡើយ។

១៦. តាមគោលបំណងនៃការបង្ខាំងខ្លួន មាត្រា ៤ នៃអនុសញ្ញាណទីក្រុងហ្សឺណែវ IV តម្រូវថា ជនស៊ីវិល មិនមែនជាសញ្ជាតិរបស់ភាគីដែលពួកគាត់ស្ថិតនៅក្រោមដៃឡើយទេ[30]។ យុត្តិសាស្ត្រអន្តរជាតិ បានបញ្ជាក់ថា លក្ខខណ្ឌតម្រូវផ្នែកសញ្ជាតិនេះជាទូទៅមិនអាចឈ្នះលើ"សេចក្តីស្មោះត្រង់" និង"កិច្ចការពារប្រកបដោយប្រសិទ្ធភាព" ជាលក្ខខណ្ឌតម្រូវសមស្របជាង[31]។ ក្នុងករណីនេះ កង្វះកិច្ចការពារប្រកបដោយប្រសិទ្ធភាពពីសំណាក់ភាគីខ្លួនឯង (អាចបកស្រាយតាមសទិសភាពម្យ៉ាងទៀតថា មិនមានសញ្ជាតិដូចភាគីវាយប្រហារនោះ) បង្ហាញឱ្យឃើញថា ទាហានអាចត្រូវចាត់ទុកថាជា"ជនត្រូវការពារ"តាមគោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ហេតុនេះ ពួកគាត់ត្រូវបានការពារក្នុងនាមជាជនស៊ីវិល ត្រង់ចំណុចនេះ។

---

[29] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ សេចក្តីណែនាំបកស្រាយស្តីពីសញ្ញាណអំពីការចូលរួមផ្ទាល់នៅក្នុងសកម្មភាពអរិភាពក្រោមច្បាប់មនុស្សធម៌អន្តរជាតិ Nils Melzer ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៤៦។ (យើងប្រើប្រាស់សេចក្តីណែនាំនេះសម្រាប់តែគោលបំណងបកស្រាយសញ្ញាណមួយដែលចូលជាធរមានរួចហើយនៅឆ្នាំ ១៩៧៥)។

[30] សូមមើលមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV។

[31] សូមមើល សាលដីកា រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Dusko Tadic រឿងក្តីលេខ IT-94-1-A តុលាការ ICTY អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៦៣-១៦៩៖ *<u>"នៅឆ្នាំ ១៩៤៩ រួចហើយទៅ ចំណងផ្លូវច្បាប់អំពីសញ្ជាតិមិនត្រូវបានចាត់ទុកថាមានសារៈសំខាន់ឡើយ ហើយមានការអនុញ្ញាតសម្រាប់រឿងក្តីពិសេសៗ។</u> នៅក្នុងរឿងក្តីជនភៀសខ្លួនខាងលើ <u>កង្វះសេចក្តីស្មោះត្រង់ចំពោះរដ្ឋណាមួយ និងកង្វះកិច្ចការពារការទូតពីរដ្ឋនេះ ត្រូវចាត់ទុកថាមានសារៈសំខាន់ជាងទំនងទំនងផ្លូវការអំពីសញ្ជាតិ"</u>* (កថាខណ្ឌ ១៦៥)។

១៧. ហេតុនេះ អាចធ្វើសេចក្ដីសន្និដ្ឋានថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធ មិនត្រូវចាត់ទុកថាជាយុទ្ធជនឡើយ ប៉ុន្តែជាជនស៊ីវិលចំពោះរដ្ឋខ្លួនឯង[32]។

ខ) សមាជិកនៃកងកម្លាំងប្រដាប់អាវុធក្នុងនាមជាទាហាន“**បាត់បង់សមត្ថភាពប្រយុទ្ធ**”

១៨. ជាចុងក្រោយ មានទទ្បីករណ៍ថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីណាមួយនៅក្នុងជម្លោះអាចត្រូវចាត់ទុកថាបានបាត់បង់សមត្ថភាពប្រយុទ្ធចំពោះភាគីខ្លួនឯង។

១៩. និយមន័យអំពីពាក្យថា “បាត់បង់សមត្ថភាពប្រយុទ្ធ” តម្រូវថា ជននោះ*“បានទម្លាក់អាវុធ ហើយស្ថិតក្នុងស្ថានភាពបាត់បង់សមត្ថភាពប្រយុទ្ធ ដោយសារជំងឺ របួស ការឃុំខ្លួន និងមូលហេតុណាផ្សេងទៀត ”*[33]។ នៅក្នុងស្ថានភាពនេះ ទាហានស្ថិតក្នុងស្ថានភាពបាត់បង់សមត្ថភាពប្រយុទ្ធយ៉ាងច្បាស់ នៅពេលដែលជាប់ឃុំខ្លួនភ្លាម។ ឬក៏គេអាចផ្ដល់ទទ្បីករណ៍ថា ដោយសារជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីខ្លួនឯង(“មូលហេតុណាផ្សេងទៀត”) ទើបទាហានទាំងនោះជាលក្ខណៈអត្តនោម័តគឺបានបាត់បង់សមត្ថភាពប្រយុទ្ធចំពោះភាគីខ្លួនឯងហើយ ប្រសិនបើពួកគេមិនមានសកម្មភាពអរិភាពប្រឆាំងនឹងភាគីខ្លួនឯងទេ។

២០. ដោយបាត់បង់សមត្ថភាពប្រយុទ្ធ ទាហានត្រូវតែចាត់ទុកថាជាជនស៊ីវិល និងត្រូវការពារតាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានបញ្ជាក់ដោយយុត្តិសាស្ត្រនេះ[34]។

---

[32] ដូចបានទទួលស្គាល់ដោយការសិក្សាច្បាប់ទម្លាប់អន្តរជាតិធ្វើឡើងដោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ វិធាន ១៖ ភាគីនៅក្នុងជម្លោះត្រូវតែបែងចែកឱ្យខុសគ្នារវាងជនស៊ីវិល ជាមួយនឹងយុទ្ធជននៅគ្រប់ពេលទាំងអស់ ជាគោលការណ៍ដែលមានចែងដំបូងនៅក្នុងសេចក្ដីប្រកាស St. Petersburg (ឆ្នាំ ១៨៦៨)។

[33] មាត្រា ៣ រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវ។

[34] តុលាការកំពូលអាល្លឺម៉ង់ (Obserster Gerichshof) ភូមិភាគកាន់កាប់ដោយចក្រភពអង់គ្លេស រឿងក្ដី *R* ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៤៨។ តុលាការកំពូលអាល្លឺម៉ង់ (Obserster Gerichshof) ភូមិភាគកាន់កាប់ដោយចក្រភពអង់គ្លេស រឿងក្ដី *P និងអ្នកផ្សេងទៀត* ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៤៨។ តុលាការជាន់ខ្ពស់បារាំង (អង្គជំនុំជម្រះតុលាការព្រហ្មទណ្ឌ) រឿងក្ដី Touvier ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩២ កថាខណ្ឌ ៣៣៨។ តុលាការ ICTY រឿងក្ដី រដ្ឋអាជ្ញាតទល់នឹង Tadić, សំណុំរឿងលេខ IT-94-1-T សាលក្រម ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៦៤៨។ រឿងក្ដី រដ្ឋអាជ្ញាតទល់នឹង Jelsić, សំណុំរឿងលេខ IT-95-10-T អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤។ រឿងក្ដី រដ្ឋអាជ្ញាតទល់នឹង Blaškić, IT-95-14-T, សាលក្រម ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ២១៤។ រឿងក្ដី រដ្ឋអាជ្ញាតទល់នឹង Kordić និង Cerkez, IT-95-14/2-A, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ៤២១។ រឿងក្ដី រដ្ឋអាជ្ញាតទល់នឹង Akayesu, ICTR-96-4-T, ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨២។ រឿងក្ដី រដ្ឋអាជ្ញាតទល់នឹង Sesay និងអ្នកផ្សេងទៀត(SCSL-04-15-T) ថ្ងៃទី ០២ ខែ មីនា ឆ្នាំ

សេចក្តីសន្និដ្ឋាន

២១. មានការអះអាងថា យោងតាមច្បាប់ទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចម្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បទដ្ឋានច្បាប់ត្រឹមត្រូវដើម្បីបកស្រាយទស្សនាទានស្តីពី *"ប្រជាជនស៊ីវិល"* តាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺរាប់បញ្ចូលទាំងការវាយប្រហាររបស់រដ្ឋ ឬអង្គការមកលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធខ្លួនឯង។

២២. សេចក្តីសន្និដ្ឋាននេះមិនត្រឹមតែស៊ីសង្វាក់គ្នាជាមួយនឹងមូលហេតុដើមនៃការរៀបចំក្រមអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងវត្ថុបំណង និងគោលបំណងនៃវិធាននៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិប៉ុណ្ណោះទេ[35] ប៉ុន្តែវាក៏ឆ្លុះបញ្ចាំងពីការវិវត្តនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដូចបានរៀបចំជាក្រមនៅក្នុងសេចក្តីព្រាងនៃក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិឆ្នាំ ១៩៥៤ ដែលមិនមានការលើកឡើងពីប្រជាជនស៊ីវិលនៅក្នុងចំណោមធាតុផ្សំបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[36]។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ | TRIAL | ទីក្រុង ហ្សឺណែវ ប្រទេសស្វីស | *[ហត្ថលេខា]* |

២០០៩ កថាខណ្ឌ ៨២។ ក្នុងរឿងក្តីភាគច្រើនក្នុងចំណោមរឿងក្តីទាំងនេះ និយមន័យអំពីប្រជាជនដែលត្រូវការពារតាមគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺមានន័យកាន់តែទូលាយ រាប់បញ្ចូលផងដែរទាំងជនស៊ីវិលដែលមិនចូលរួមក្នុងសកម្មភាពអរិភាព ហើយនៅក្នុងរឿងក្តីនានារបស់តុលាការកំពូលអាល្លឺម៉ង់ ក៏រាប់បញ្ចូលទាំងទាហានផងដែរ។

[35] Casses A ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ មតិយោបល់ស្តីពីចំណុចបញ្ហាមួយចំនួន ឯកសារ Casses, A ផ្នែកមនុស្សនៃច្បាប់អន្តរជាតិ សារណាសម្រិតសម្រាំង សារព័ត៌មានសាកលវិទ្យាអុកស្វ៊ដ ឆ្នាំ ២០០៨ ទំព័រ ៤៦៦។

[36] គណៈកម្មការច្បាប់អន្តរជាតិ សេចក្តីព្រាងនៃក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ ឆ្នាំ ១៩៥៤ មាត្រា ២ កថាខណ្ឌ ១០។ សូមមើលអត្ថបទទាំងស្រុងនៅ http://legal.un.org/ilc/texts/instruments/english/commentarites/7_3_1954.pdf។